YUNNAN DAILY PRESS GROUP
No.164

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

khmerlight@163.com
english.yunnan.cn

ឆ្នាំទី 26 លេខ 7712 ថ្ងៃសុក្រ ទី 17 ខែ សីហា ឆ្នាំ 2018

## ពិព័រណ៍ឧស្សាហកម្មវប្បធម៌ "គំនិតច្នៃប្រឌិតខេត្តយូនណាន" ឆ្នាំ២០១៨



*ការសម្តែងតន្ត្រីជនជាតិនៅក្នុងអំឡុងកម្មវិធីពិព័រណ៍ដែលមានការទាក់ទាញ (រូបថតដោយ Yang Zheng )*

ព្រឹកថ្ងៃទី៩ ខែសីហា ឆ្នាំ២០១៨ ពិព័រណ៍ឧស្សាហកម្មវប្បធម៌"គំនិតច្នៃប្រឌិតខេត្តយូនណាន" ឆ្នាំ២០១៨ បានបើកពិព័រណ៍ជាផ្លូវការនៅខេត្តយូនណាន។ វត្ថុសិប្បកម្មចម្លាក់យក់ស្នាដៃវិចិត្រសិល្បៈផលិតផលវិទ្យាសាស្ត្រឈានមុខវប្បធម៌ គំនូរជីវចលយុវជន និងផលិតផលឧស្សាហកម្មវប្បធម៌ជាដើមបានត្រូវដាក់តាំងពិព័រណ៍ក្នុងឱកាសពិព័រណ៍នេះ ។ ពិព័រណ៍នេះបានបង្ហាញឱ្យឃើញពីការរីកចម្រើននៃឧស្សាហកម្មវប្បធម៌ខេត្តយូនណាន ព្រមទាំងវប្បធម៌ដ៏ក្រាស់ក្រែលនិងជំនឿចិត្តយ៉ាងរឹងមាំរបស់ខេត្តយូនណាន ដើម្បីដើរឆ្ពោះទៅកាន់អនាគត ។

សហគ្រាសវប្បធម៌ជាតិ និងអន្តរជាតិចំនួនជាង១.២០០សហគ្រាសបានចូលរួមក្នុងពិព័រណ៍នេះ ។ នេះបានធ្វើឱ្យពិព័រណ៍នេះក្លាយទៅជាកម្មវិធីផ្លាស់ប្តូរវប្បធម៌ដ៏អធិកអធមនិងជាទិវាវប្បធម៌ដែលមានប្រជាប្រិយភាពក្នុងសង្គម ។ ពិព័រណ៍វប្បធម៌នេះជាពិព័រណ៍មួយដែលប្រកបដោយគំនិតច្នៃប្រឌិតលក្ខណៈពិសេស និងកម្លាំងទាក់ទាញ ។ ក្នុងពន្លាពិព័រណ៍វប្បធម៌និងបច្ចេកវិជ្ជា(ពន្លាពិព័រណ៍លេខ៦) អ្នកទស្សនាអាចទស្សនាដោយផ្ទាល់ភ្នែកនូវប្រជុំសំណង់បុរាណរបស់ក្រុងគុនមីង តាមរយៈបច្ចេកទេស VR, AR,CR ហើយនឹងអាចមានការយល់ដឹងកាន់តែច្បាស់អំពីប្រវត្តិសាស្ត្របុរាណ។

ត្បូងយក់របស់ខេត្តយូនណានមានឈ្មោះល្បីល្បាញទាំងក្នុងនិងក្រៅប្រទេសចិន ។ ពន្លាពិព័រណ៍លេខ១ សម្រាប់ដាក់តាំងពិព័រណ៍នូវផលិតផលរតនវត្ថុបានទទួលនូវការចាប់អារម្មណ៍ពីសំណាក់អ្នកទស្សនាជាតិនិងអន្តរ-ជាតិ ។ វត្ថុសិប្បកម្មចម្លាក់ត្បូងយក់ ត្បូងទទឹម ត្បូងកណ្តៀង និងគជ់ដែលត្រូវបានដាក់តាំងបង្ហាញក្នុងពិព័រណ៍ទាំងនោះបានទាក់ទាញក្រសែភ្នែករបស់អ្នកចូលចិត្តចម្លាក់ត្បូងច្រើន ។ ក្នុងពន្លាពិព័រណ៍លេខ២ សម្រាប់ដាក់តាំងពិព័រណ៍នូវវត្ថុសិប្បកម្មវិចិត្រសិល្បៈជាងសិប្បកម្មជាង២០រូបដែលមកពីប្រទេសចិន ជប៉ុន និងកូរ៉េខាងត្បូងបាននាំយកវត្ថុសិប្បកម្មប្រណីតចំនួនជាង ១០០ មកចូលរួមពិព័រណ៍វប្បធម៌ខេត្តយូនណាននេះដែលបានទទួលការចាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អ្នកទស្សនាគ្រប់ៗគ្នា ។

ពិព័រណ៍វប្បធម៌នេះបានទាក់ទាញពាណិជ្ជករនិងអ្នកទស្សនាដ៏ច្រើនសន្ធឹក-សន្ធាប់។ក្នុងឱកាសនេះទំនៀមទម្លាប់ប្រពៃណីនិងភាពទាន់សម័យបុរាណ-កាលនិងបច្ចុប្បន្នកាលបច្ចេកវិជ្ជានិងគំនិតច្នៃប្រឌិតបានត្រូវច្របាច់បញ្ចូល គ្នាយ៉ាងស៊ីជម្រៅ។ នេះបានបញ្ជាំងឱ្យឃើញពីសក្តានុពលដ៏ធំធេងនិងកម្លាំង ទាក់ទាញដ៏រស់រវើករបស់ឧស្សាហកម្ម វប្បធម៌នៃខេត្តយូនណាន ។៕ **ដោយហួរ ធីងធីង**

## "ខ្ញុំជាប់ចិត្តនឹងក្រុងលីជាំង"

កាលពីថ្ងៃទី២៧ ដល់ទី២៩ ខែកក្កដា ឆ្នាំ២០១៨ មន្ត្រីការទូតនិងបុគ្គលិកការងារនៃអង្គការសហប្រជា-ជាតិជាង៤០ រូបដែលចូលរួម"កម្មវិធីទស្សនាប្រទេសចិននៃអង្គការសហ-ប្រជាជាតិឆ្នាំ២០១៨"បានអញ្ជើញទៅបំពេញទស្សនកិច្ចនៅក្រុងលីជាំងនៃខេត្តយូនណាន ដើម្បីចូលរួមសកម្មភាពផ្លាស់ប្តូរផ្នែកវប្បធម៌នៅទីនោះ ។

ក្នុងអំឡុងពេល៣ថ្ងៃនោះ តំណាងដែលមកពីអង្គការសហប្រជា-ជាតិ បានមានការស្វែងយល់យ៉ាងស៊ីជម្រៅអំពីវប្បធម៌តុងប៉ារបស់ជនជាតិណាស៊ី ។ ពួកគេបានទៅទស្សនាក្រុងបុរាណលីជាំង ប្រជុំភូមិបុរាណសាន-គូសួយ ផ្លូវបុរាណតែ និងសេះភ្នំព្រឹលយូឡុង និងតំបន់មួយចំនួនទៀតនៃខេត្តយូនណាន ដើម្បីសិក្សាស្រាវជ្រាវអំពីការអភិវឌ្ឍវិស័យទេសចរណ៍ និងការថែរក្សាអេកូ-បរិស្ថានរបស់ខេត្តយូនណាន ។ មិនតែប៉ុណ្ណោះ ពួកគេបានទទួលអារម្មណ៍ដោយផ្ទាល់អំពីសម្រស់ស្អាតនៃអេកូ-បរិស្ថាន ទីក្រុងតំបន់ជនបទ និងទេសភាពធម្មជាតិរបស់ខេត្តយូនណាន ។

បើនិយាយអំពីចំណាប់អារម្មណ៍ចំពោះខេត្តយូនណាន លោកសុត សាម្ហូឡេនស៍ ម៉ានសុល ដែលជាអ្នកសម្របសម្រួលគម្រោងពិសេសនៃផ្នែកព័ត៌មានអង្គការសហប្រជាជាតិបានបញ្ចេញនូវស្នាមញញឹមភ្លាមៗថា ខ្ញុំជាប់ចិត្តនឹងក្រុងលីជាំង! លីជាំងពិតជាស្អាតមែន ។ ខ្ញុំគិតថា ពេលវេលាវាមិនគ្រប់គ្រាន់ទេ ។ ទីនេះមានទេសភាពស្អាតនៅគ្រប់ទីកន្លែង ដែលបានធ្វើឱ្យគេជក់ចិត្តជិតអារម្មណ៍ជាខ្លាំងហើយមិនចង់ត្រឡប់ទៅវិញទៀតផង។ លោកបណ្ឌិតហ៊ឺ យ៉ុងអ្នកទទួលខុសត្រូវនៃកម្មវិធីទស្សនាប្រទេសចិននៃអង្គការសហប្រជាជាតិបានប្រាប់អ្នកកាសែតថា មានសមាជិកគណៈប្រតិភូច្រើនរូបបានប្រាប់គាត់ថាចង់មកទស្សនាក្រុងលីជាំងម្តងទៀតពីព្រោះទីនេះពិតជាស្អាតមែន ។

លោកអាក់ ក្រាម ដែលមកពីផ្នែកគ្រប់គ្រងមហាសន្និបាតនិងសន្និសីទនៃអង្គការសហប្រជាជាតិបានថ្លែងថា នេះជាលើកទី២ ដែលខ្ញុំមកដល់ខេត្តយូនណាន តែជាលើកទី១ ដែលខ្ញុំមកទស្សនាក្រុងលីជាំង ។ ខ្ញុំចូលចិត្តទេស-ភាព វប្បធម៌ ម្ហូបអាហារ និងអាកាស-ធាតុរបស់ខេត្តយូនណាន ហើយសង្ឃឹមថានឹងអាចមកទស្សនាខេត្តយូនណានម្តងទៀត ។ ក្រៅពីនេះខ្ញុំសង្ឃឹមថានឹងអាចមានជនបរទេសកាន់តែច្រើនមានការយល់ដឹងអំពីវប្បធម៌ជនជាតិណាស៊ី ។៕

## និស្សិតខ្មែរដែលបន្តវិជ្ជានៅប្រទេសចិនរស់នៅក្នុងប្រទេសចិនពិតជាមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅមក

ឆ្នាំនេះជាខួបលើកទី៤០ នៃការអនុវត្តគោលនយោបាយកែទម្រង់និងបើកចំហ ។ បើនិយាយចំពោះនិស្សិតខ្មែរឈ្មោះសុខ បញ្ញា ដែលបានបន្តវិជ្ជានៅប្រទេសចិន៧ឆ្នាំហើយនោះ គាត់តែងតែបង្ហាញ មេដៃដើម្បីកោតសរសើរចំពោះការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ប្រទេសចិន ។

នៅឆ្នាំ២០១២ សុខ បញ្ញា បានមកបន្តវិជ្ជានៅប្រទេសចិន។ ពេលនេះគាត់កំពុងរៀនថ្នាក់បណ្ឌិត នៅសាកលវិទ្យាល័យគរុកោសល្យភាគឦសានប្រទេសចិន។ គាត់បានប្រាប់អ្នកកាសែតថា ខ្ញុំធ្លាប់ឮគ្រូ និងមិត្តរួមថ្នាក់របស់ខ្ញុំថា ក្នុងរយៈពេល៤០ឆ្នាំកន្លងទៅនោះ មធ្យោបាយធ្វើដំណើររបស់ជនជាតិចិនបានផ្លាស់ប្តូរយ៉ាងច្រើន។ តាំងពីធ្វើដំណើរដោយជើងទាំងគូ ដល់ជិះកង់ តាំងពីរថភ្លើងពណ៌បៃតងដែលមានល្បឿនយ៉ាងយឺតដល់រថភ្លើងល្បឿនលឿនដ៏ទំនើបពិតជាមានការផ្លាស់ប្តូរច្រើន។

សុខ បញ្ញា បានបន្តទៀតថា ខ្ញុំពិតជាមានសំណាងល្អណាស់! ពីព្រោះនៅពេលខ្ញុំមកសិក្សានៅប្រទេសចិន ប្រទេសចិនបានទទួលការរីកចម្រើនច្រើនគួរឱ្យកត់សម្គាល់ក្នុងការសាងសង់ផ្លូវរថភ្លើងល្បឿនលឿន។នៅប្រទេសចិនរថភ្លើងអាចធ្វើដំណើរក្នុងល្បឿន ៣៥០ គីឡូម៉ែត្រ/ម៉ោង។ អ្នកដំណើរអាចទិញបានសំបុត្រដោយប្រើទូរស័ព្ទរបស់ខ្លួន។ នេះពិតជាធ្វើឱ្យគេភ្ញាក់ផ្អើលជាខ្លាំង។

សុខ បញ្ញា បានបញ្ជាក់ថា ក្រៅពីផ្លូវរថភ្លើងល្បឿនលឿន នៅមានផ្លូវល្បឿនលឿន ។ ផ្លូវល្បឿនលឿនរបស់ប្រទេសចិនបានបង្កើតជាបណ្តាញផ្លូវ "៥ខ្សែបញ្ឈរ និង៥ខ្សែផ្តេក" ដែលអាចតភ្ជាប់គ្រប់ទីក្រុងក្នុងប្រទេសចិន។ បើជិះឡានក្រុងចំណាយប្រាក់មិនច្រើនទេ ហើយក៏មានសុវត្ថិភាពដែរ ។

សុខ បញ្ញា បានរំលឹកឡើងវិញថា កាលពីមុន បើធ្វើដំណើរពីខេត្តជីលីននៃប្រទេសចិនទៅប្រទេសកម្ពុជាវិញ ខ្ញុំត្រូវជិះយន្តហោះទៅក្រុងសៀងហៃ ឬក្វាងចូវ រួចប្តូរយន្តហោះទៅរាជធានីភ្នំពេញ។ តែពេលនេះខ្ញុំមានជម្រើសច្រើនជាងមុន ពីព្រោះមានទីក្រុងកាន់តែច្រើនរបស់ប្រទេសចិនបានបើកជើងហោះហើរត្រង់ទៅប្រទេសកម្ពុជា។ ចំណែកសំបុត្រយន្តហោះក៏មានតម្លៃថោកជាងមុនដែរ។

សុខ បញ្ញា បាននិយាយថា នៅប្រទេសចិន យើងអាចជិះឡានក្រុង តាក់ស៊ី រថភ្លើងក្រោមដី ឬក៏ហៅតាក់ស៊ីនិងជួលកង់សាធារណៈតាមទូរស័ព្ទ។ បច្ចុប្បន្នបើរស់នៅក្នុងប្រទេសចិនពិតជាមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅមក!៕ **ដោយ លីវ យ៉ុង**

## ខេត្តយូនណានរៀបចំទិវាម្ហូបអាហារឆ្ងាញ់ផ្សិតព្រៃ



*ផ្សិតលិញជឺ ដែលគេល្បីថា ស្តេចផ្សិតនៅក្នុងពិធីមហោស្រពអាហារ (រូបថតដោយ Xinhua )*

នៅថ្ងៃទី៨ ខែសីហា ឆ្នាំ ២០១៨ ទិវាវប្បធម៌ម្ហូបអាហារឆ្ងាញ់ផ្សិតព្រៃណានហួ ប្រទេសចិនលើកទី១៥ បានរៀបចំនៅស្រុកណានហួនៃខេត្តយូនណាន ប្រទេសចិន។ នៅខែសីហា ដែលជាខែសម្បូរផ្សិតព្រៃនេះ ការប្រកួតម្ហូបអាហារផ្សិតព្រៃ និងការប្រកួត "ស្តេចផ្សិត" ដែលរៀបចំនៅខេត្តយូនណាននេះបានទទួលការចាប់-អារម្មណ៍ពីទេសចរជាតិ និងអន្តរជាតិដែលមកដើរលេងខេត្តយូនណាន។ ក្នុងការប្រកួត"ស្តេចផ្សិត" គេបានជ្រើសរើស "ស្តេចផ្សិត" នៃផ្សិតគ្រប់ប្រភេទ ដូចជាផ្សិតសុងយ៉ុង ផ្សិតឃួជូន ផ្សិតថ្មើមគោ ផ្សិតជើងខ្លា ផ្សិតលីងជឺ ផ្សិតកាន់ប៉ា និងផ្សិតជីជុង ជាដើម ។៕

(**ស៊ីនហួចិន**)

## ខេត្តយូនណានបង្កើនជើងហោះហើរទៅតំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍

ពេលថ្មីៗនេះ គណៈកម្មាធិការកែទម្រង់និងអភិវឌ្ឍន៍ខេត្តយូនណាន និងមន្ទីរអភិវឌ្ឍន៍ និងគ្រប់គ្រងអាកាស-ចរណ៍ស៊ីវិលខេត្តយូនណានបានរៀបចំសិក្ខាសាលាស្តីពីគម្រោងផ្តល់ប្រាក់បន្ថែមដល់ការបង្កើត និងបង្កើនជើងហោះហើរអន្តរជាតិទៅកាន់តំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ឆ្នាំ ២០១៨-២០២០ ដើម្បីផ្សព្វផ្សាយអំពីគោលនយោបាយជំរុញការបង្កើនជើងហោះហើរអន្តរជាតិខេត្តយូនណាន និងគម្រោងផ្តល់ប្រាក់បន្ថែមដល់ការបង្កើត និងបង្កើនជើងហោះហើរអន្តរជាតិទៅកាន់តំបន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ។





*អ្នកដំណើរកំពុងតែបោះជំហានចូលទីក្រុងគុនមិញ តាមរយៈ អាកាសយានដ្ឋានអន្តរជាតិ (រូបថត ដោយ Zhang Tong )*

គួរបញ្ជាក់ថា គិតមកដល់ចុងខែមិថុនា ឆ្នាំ២០១៨ ខេត្តយូនណានបានបង្កើតខ្សែផ្លូវអាកាសចរណ៍អន្តរជាតិចំនួន៨៧ខ្សែ កើនឡើង២៧ខ្សែ ធៀបនឹងឆ្នាំ២០១៤ ដែលបានគ្របដណ្តប់លើរដ្ឋធានី និងរាជធានីនៃគ្រប់ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍។ ក្នុងចន្លោះពីឆ្នាំ២០១៨ដល់ឆ្នាំ២០២០ ខេត្តយូនណាន នឹងខិតខំជំរុញការបង្កើតជើងហោះហើរពីក្រុងគុនមីងទៅរដ្ឋធានីអ៊ិស្លាម៉ាបាដ នៃប្រទេសប៉ាគីស្ថាន រដ្ឋធានីហ្សាកាតានៃប្រទេសឥណ្ឌូណេស៊ី ទីក្រុង Mumbai ទីក្រុង Hai Phong និងទីក្រុងគុចហិន ជាដើម។ ក្នុងនោះមានខ្សែផ្លូវអាកាសចរណ៍ដឹកអ្នកដំណើរ១៧ខ្សែ និងខ្សែផ្លូវអាកាស-ចរណ៍ដឹកទំនិញ៨ខ្សែ (Kolkata, Colombo, Rangoon) ព្រមទាំងខ្សែផ្លូវអាកាសចរណ៍អន្តរជាតិសំខាន់៣០ខ្សែ ដែលហោះហើរពីខេត្តយូនណានទៅប្រទេសអាស៊ីខាងត្បូង និងអាស៊ី-អាគ្នេយ៍ ។៕ **ដោយ យ៉ាង ស៊ូយ៉ាន**